**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: [illegible] សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ២០១១

# ប្រកាស
## ស្តីពី
## ការលើកលែងពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១១ ចំពោះសង្កាត់មួយចំនួនក្នុងរាជធានីភ្នំពេញ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃ២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៣៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ
- យោងតាមការចាំបាច់ក្នុងការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១១

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com
Collection by VCAT Professional Consultant

## សម្រេច

**ប្រការ១.** ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១១ ចំពោះអចលនទ្រព្យដែលស្ថិតក្នុងសង្កាត់ចំនួន ២០ (ម្ភៃ) ក្នុងខណ្ឌមួយចំនួននៃរាជធានីភ្នំពេញ ដូចខាងក្រោម ៖

១. ខណ្ឌសែនសុខ ៖ សង្កាត់ចំនួន ០៣ (បី) គឺសង្កាត់ព្រែកព្នៅ សង្កាត់សំរោង និងសង្កាត់ពញាពន់ ។

២. ខណ្ឌដង្កោ ៖ សង្កាត់ចំនួន ១១ (ដប់មួយ) គឺសង្កាត់ពន្សាំង សង្កាត់ស្នោរ សង្កាត់ឪឡោក សង្កាត់បឹងធំ សង្កាត់កំបូល សង្កាត់កន្ទោក សង្កាត់គងនយ សង្កាត់ទៀន សង្កាត់ល្វេស សង្កាត់ស្ពានថ្ម និងសង្កាត់ព្រែកកំពឹស ។

៣. ខណ្ឌមានជ័យ ៖ សង្កាត់ចំនួន ០៤ (បួន) គឺសង្កាត់វាលស្បូវ សង្កាត់ព្រែកឯង សង្កាត់ក្បាលកោះ និងសង្កាត់ព្រែកថ្មី ។

៤. ខណ្ឌឫស្សីកែវ ៖ សង្កាត់ចំនួន ០២ (ពីរ) គឺសង្កាត់បាក់ខែង និងសង្កាត់កោះដាច់ ។

**ប្រការ២.** ម្ចាស់អចលនទ្រព្យដែលស្ថិតក្នុងសង្កាត់ចំនួន ២០ នៃខណ្ឌចំនួន ៤ ដូចប្រការ ១ ខាងលើ ពុំមានកាតព្វកិច្ចដាក់លិខិតព័ត៌មាន លិខិតចុះបញ្ជី និងលិខិតប្រកាសពន្ធលើអចលនទ្រព្យទេ ។

**ប្រការ៣.**

១. ក្នុងករណីអចលនទ្រព្យក្នុងសង្កាត់ទាំង ២០ ដែលបានលើកលែងដូចខាងលើ បានបង់ពន្ធលើអចលនទ្រព្យរួចហើយ ចំនួនប្រាក់ពន្ធដែលបានបង់រួចនោះ ត្រូវបានអនុញ្ញាតឱ្យបង្វិលសងវិញ ឬធ្វើជាឥណទានសម្រាប់យកទៅបង់ពន្ធអចលនទ្រព្យសម្រាប់ឆ្នាំបន្តបន្ទាប់ ។

២. សម្រាប់ការបង្វិលសង សាខាពន្ធដារខណ្ឌ ត្រូវធ្វើការបង្វិលសងទៅម្ចាស់អចលនទ្រព្យវិញ ដោយប្រើប្រាស់ទឹកប្រាក់ពន្ធអចលនទ្រព្យដែលប្រមូលបានក្នុងថ្ងៃ ។

៣. ម្ចាស់អចលនទ្រព្យ ត្រូវធ្វើការស្នើសុំបង្វិលសងតាមទម្រង់ដែលបានកំណត់ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ផុតកំណត់នេះ ទឹកប្រាក់ពន្ធលើអចលនទ្រព្យដែលបានបង់ត្រូវចាត់ជាឥណទានសម្រាប់យកទៅបង់ពន្ធអចលនទ្រព្យសម្រាប់ឆ្នាំបន្តបន្ទាប់ ។

**ប្រការ៤.** អគ្គលេខាធិការ អគ្គនាយកដ្ឋានពន្ធដារ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងសាលារាជធានីភ្នំពេញ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ

Collection by VCAT Professional Consultant